Guide.qxp 1/03/2005 4:10 PM Page 7

# សេចក្តីផ្តើម

## សាវតារ

វាយតំលៃលើការអប់រំសំរាប់ទាំងអស់គ្នាឆ្នាំ ២០០០ បានបង្ហាញថា ការលើកកំពស់ការចូលរៀននៅបឋមសិក្សាមានការរីកចំរើន ហើយនៅកន្លែងខ្លះមានការរីកចំរើនគួរឱ្យកត់សំគាល់ ។ ប៉ុន្តែ ការបង្រួញគម្លាតយេនឌ័រនៅកន្លែងជាច្រើនបានសំរេចបន្តិចបន្តួច ឬ មិនបានសំរេចសោះ។ នៅពេលដែលរដ្ឋាភិបាលនានាឃើញលទ្ធផលរកឃើញទាំងនេះ កាលពីនៅវេទិកាអប់រំពិភពលោកនៅក្រុងដាកា ប្រទេសសេនេហ្គាល ខែមេសា ឆ្នាំ ២០០០ រដ្ឋាភិបាលទាំងនោះ បានសំរេចបង្កើនការខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីលុបបំបាត់គម្លាតយេនឌ័រ ហើយបានប្តេជ្ញាថា សំរេចសមភាពយេនឌ័រឱ្យបាននៅឆ្នាំ២០១៥។ នៅពិធីបើកសន្និសីទនៅទីក្រុងដាកានេះ លោក កូហ្វី អាណាន់ អគ្គលេខាធិការ អង្គការសហប្រជាជាតិ បានថ្លែងសេចក្តីប្តេជ្ញាចិត្តយ៉ាងមុតមាំសំរាប់ប្រព័ន្ធអង្គការសហប្រជាជាតិទាំងអស់ឱ្យយកចិត្តទុកដាក់លើបញ្ហានេះ ដោយប្រកាសគំនិតផ្តួចផ្តើមអង្គការសហប្រជាជាតិស្តីពីការអប់រំសំរាប់កុមារី។

## ការប្តេជ្ញាចំពោះសមភាពយេនឌ័រ នៅទីក្រុងដាកា ខែមេសា ឆ្នាំ២០០០

**គោលដៅទី ២:** ធានាថានៅឆ្នាំ២០១៥ កុមារទាំងអស់ជាពិសេស កុមារីមានលទ្ធភាពទទួលការអប់រំ និង បញ្ចប់ការអប់រំប្រកបដោយគុណភាព ដោយឥតបង់ថ្លៃ និងដោយកាតព្វកិច្ច។

**គោលដៅទី ៤:** សំរេចឱ្យបាន ៥០ ភាគរយ នូវការបង្កើនកំរិតអក្ខរកម្មមនុស្សចាស់ នៅឆ្នាំ ២០១៥ ជាពិសេសសំរាប់ស្ត្រី ។

**គោលដៅទី ៥:** លុបបំបាត់វិសមភាពយេនឌ័រគិតជាតួលេខក្នុងការអប់រំបឋមសិក្សា និង មធ្យមសិក្សា ឱ្យបាននៅឆ្នាំ២០០៥ ហើយសំរេចឱ្យបានសមភាពយេនឌ័រក្នុងការអប់រំនៅឆ្នាំ២០១៥ ដោយធានាឱ្យកុមារីមានលទ្ធភាពពេញលេញ និងស្មើភាពក្នុងការទទួលការអប់រំមូលដ្ឋាន និងសំរេចជោគជ័យក្នុងការសិក្សា។

# កិច្ចព្រមព្រៀងក្នុងចំណោមបណ្តាប្រទេសនៅអាស៊ី និង ប៉ាស៊ីហ្វិកកាលពីនៅបាងកក ខែមករា ឆ្នាំ ២០០០

ក្រុមខណ្ឌសកម្មភាព[១] ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកបញ្ជាក់ថា:

*"ចាំបាច់ត្រូវលុបបំបាត់វិសមភាពយេនឌ័រក្នុងគ្រប់ប្រព័ន្ធទាំងអស់ ដែលកើតមានឡើងក្នុងចំណោមកុមារី និង កុមារាទូទាំងប្រព័ន្ធអប់រំ ដូចជាការចុះឈ្មោះចូលរៀន ការសំរេចលទ្ធផលសិក្សា និង បញ្ចប់ការសិក្សាក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូ និង បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ក្នុងកម្មវិធីសិក្សា និង ក្នុងសកម្មភាពរៀន និង បង្រៀន ។ ភាពច្បាស់លាស់តាមទារការយល់ដឹងច្បាស់ និង ឱ្យតំលៃខ្ពស់ទៅលើតួនាទីអប់រំ ដែលជាយានសំរាប់ធានាឱ្យមានសមភាពសំរាប់ស្ត្រី និង សំរាប់ផ្តល់សិទ្ធិ និង អំណាចដល់ស្ត្រី ។"*

# តើលុបបំបាត់គម្លាតយេនឌ័រ និង សមភាពយេនឌ័រ មានន័យយ៉ាងដូចម្តេច?

លុបបំបាត់គម្លាតយេនឌ័រ និង វិសមភាពយេនឌ័រ មានន័យថាធ្វើយ៉ាងណាឱ្យភាពមិនល្អរវាងភេទ មានការពេញចិត្តទាំងអស់គ្នា ។ ធានាថា ភេទទាំងពីររៀនចប់ពីសាលា មានការអប់រំមួយដែលផ្តល់នូវបំណិនជីវិត និង អនុញ្ញាតឱ្យភេទទាំងពីរបន្តការសិក្សាទៅថ្នាក់ឧត្តម ឬ ថ្នាក់វិជ្ជាជីវៈ ហើយមិនមានការបែងចែកតាមទម្លាប់មិនល្អរបស់ប្រពៃណីយេនឌ័រឡើយ។ សំខាន់ជាងគេបំផុត ភេទទាំងពីរត្រូវទទួលបានជំនាញ និង គំរូយាបថដែលធានាឱ្យគេប្រើប្រាស់សក្តានុភាពរបស់គេដោយមិនប្រកាន់ភេទ។ នៅប្រទេសភាគច្រើន កុមារីច្រើនចាត់ទុកជាភេទទន់ខ្សោយ ប៉ុន្តែតាមការពិត ក្នុងករណីខ្លះ ក៏មានក្មេងប្រុសទន់ខ្សោយជាងក្មេងស្រី នៅក្នុងប្រព័ន្ធអប់រំ និង សេដ្ឋកិច្ចសង្គមកិច្ចដែរ។ អ្នកប្រើប្រាស់ពាក្យទាំងនេះត្រូវប្រើពាក្យក្មេងប្រុស និង ក្មេងស្រី តាមដែលសមស្រប ។ សូមស្វែងយល់បន្ថែមអំពីពាក្យយេនឌ័រក្នុងវគ្គមួយនិយាយអំពីបញ្ញត្តិគន្លឹះ នៅចុងបញ្ចប់នៃឯកសារនេះ ។

១. អនុម័តនៅសន្និសីទអាស៊ីប៉ាស៊ីហ្វិកស្តីពីការវាយតម្លៃអប់រំសំរាប់ទាំងអស់គ្នាឆ្នាំ ២០០០ ក្នុងបាងកក ១៧-២០ មករា ២០០០។

## ភារកិច្ចចំពោះមុខ

ភារកិច្ចចំពោះមុខដែលត្រូវបំពេញឱ្យបានគឺ កំណែទំរង់ប្រព័ន្ធអប់រំដែលឱ្យប្រព័ន្ធនេះផ្តល់ឱកាសស្មើៗគ្នាដល់កុមារទាំងអស់ ហើយផលិតពលរដ្ឋដែលអាចចូលរួមក្នុងសមត្ថភាពដូចគ្នា ក្នុងការអភិវឌ្ឍ សង្គមប្រជាធិបតេយ្យគ្មានការរើសអើង និង មិនប្រកាន់ភេទ ។ ជំហានទីមួយ ក្នុងទិសដៅនេះគឺធានាថា ផែនការអប់រំសំរាប់ទាំងអស់គ្នាមានបញ្ចូលយេនឌ័រ និង ឆ្លើយតបនឹងតំរូវការយេនឌ័រ មានទិសដៅ និង យុទ្ធសាស្ត្រជាក់លាក់ ហើយបានទទួលមូលនិធិ និង ធនធានមនុស្សសំរាប់អនុវត្ត និង តាមដានការរីកចំរើនឈានទៅសំរេចគោលដៅទាំងអស់នេះ។ គួរកត់សំគាល់ថា ប្រទេសនានាត្រូវមានផែនការអប់រំសំរាប់ទាំងអស់គ្នាយ៉ាងលំអិតច្បាស់លាស់ត្រូវមានកម្មវិធីអប់រំសំរាប់ទាំងអស់គ្នាយ៉ាងលំអិតនៅក្នុងផែនការអភិវឌ្ឍន៍វិស័យអប់រំជាតិ ដែលឆ្លើយតបនឹងតំរូវការយេនឌ័រ ហើយមិនត្រូវមានផែនការដោយឡែកសំរាប់ការអប់រំកុមារី និង ស្ត្រីឡើយ ។ លក្ខណៈវិនិច្ឆ័យសំរាប់វាយតំលៃផែនការទាំងនេះ រួមមាន វិសាលភាពនៃតំរូវការឆ្លើយតបនឹងយេនឌ័រ ហើយនិង លក្ខណៈដែលមានឥទ្ធិពលសំរាប់ផ្តល់ មូលនិធិ ។

## បែបបទធ្វើផែនការ

ដូចមានចែងក្នុងគោលការណ៍ណែនាំរបស់អង្គការ យូណេស្កូ សំរាប់រៀបចំផែនការ[២] អប់រំសំរាប់ទាំងអស់គ្នា បែបបទធ្វើផែនការ ត្រូវមានការចូលរួមពីច្រើនភាគី និង មានកិច្ចព្រមព្រៀងរួម និង បង្កើតជាដៃគូ ។ ក្នុងន័យនេះត្រូវធានាថា អង្គការស្ត្រី និង សកម្មជនអប់រំជាស្ត្រី បានចូលរួមក្នុងវេទិកាអប់រំសំរាប់ទាំងអស់គ្នា ហើយធានាថា អ្នកជំនាញយេនឌ័រទាំងប្រុស ទាំងស្រី បានចូលរួមក្នុងក្រុមធ្វើផែនការ និង ពង្រាងផែនការសំខាន់ ដូចគ្នានេះដែរ គឺធ្វើយ៉ាងណាឱ្យអ្នកចែងគោលនយោបាយទាំងប្រុស ទាំងស្រី យល់អំពីបញ្ហាយេនឌ័រ ដូច្នេះ អ្នកចែងគោលនយោបាយនឹងចាត់ទុកថា ការអប់រំដែលមានបញ្ចូលយេនឌ័រពិតជាមានសារប្រយោជន៍សំរាប់អ្នករៀនទាំងប្រុសទាំងស្រី និង សំរាប់សង្គមទាំងមូល ។

---

២ ការរៀបចំផែនការសកម្មភាពជាតិ : សេចក្តីណែនាំប្រចាំប្រទេស UNESCO 2000